LONGBEACH
HEALTH & HUMAN SERVICES

**បច្ចុប្បន្នភាពថ្មីៗ:**

- គឺតត្រឹមថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០២១, ខោនធីឡូសអាន់ជេឡេស, រួមទាំងទីក្រុងឡុងប៊ីច គឺបានដាក់អោយស្ថិតនៅចំណាត់ថ្នាក់ពណ៌ក្រហម ក្រោមផែនការមេរបស់រដ្ឋ ចំពោះសេដ្ឋកិច្ចដែលមានសុវត្ថិភាពជាងមុន។ ជាលទ្ធផលនៃការផ្លាស់ប្តូរចំណាត់ថ្នាក់នេះ មិនមានការផ្លាស់ប្តូរអ្វីឡើយ ចំពោះពិធីសារនេះ។

# ពិធីការសារមន្ទីរ, វិចិត្រសាល, និងអាងចិញ្ចឹមត្រី: ឧបសម្ព័ន្ធ P

**ធ្វើបច្ចុប្បន្នភាព ថ្ងៃទី 3/12/21:**

- ក្រុងឡុងប៊ីច គឺដាក់អោយស្ថិតនៅចំណាត់ថ្នាក់ពណ៌ក្រហម ក្រោមផែនការមេរបស់រដ្ឋ ចំពោះសេដ្ឋកិច្ចដែលមានសុវត្ថិភាពជាងមុន។ ចំណុះ ឬការកាន់កាប់ខាងក្នុង និងខាងក្រៅសារៈមន្ទីរ ត្រូវបានកំណត់ត្រឹម ២៥% នៃការកាន់កាប់អតិបរមា។ សារៈមន្ទីរ, វិចិត្រសាល និងអាងចិញ្ចឹមត្រី អាចបើកធ្វើប្រតិបត្តិការបាន នៅខាងក្នុង និងខាងក្រៅ។ ការធ្វើបច្ចុប្បន្នភាពអំពីការអនុញ្ញាតិនូវព្រឹត្តិការណ៍សំដែងផ្ទាល់នៅខាងក្រៅសារៈមន្ទីរ ដែលមានប្រសិទ្ធភាព ចាប់ពីថ្ងៃទី ១ ខែមេសា ឆ្នាំ ២០២១។ ការផ្លាស់ប្តូរនានា បានរំលេចជាពណ៌លឿង។

ពិធីការនេះ នឹងត្រូវបានបំពេញ ដោយសារមន្ទីរ, សារមន្ទីរកុមារ, វិចិត្រសាល, សួនច្បាររុក្ខសាស្ត្រ, អាងចិញ្ចឹមត្រី, និងកន្លែងស្រដៀងគ្នាផ្សេងៗទៀត (ជារួមហៅថា "សារមន្ទីរ") ។ បន្ថែមលើល័ក្ខខ័ណ្ឌនានា ដែលបានដាក់លើកន្លែងជាក់ទាំងនេះ ដោយមន្ត្រីសុខភាពសាធារណៈរដ្ឋ, ដែលមាន ឬមើលឃើញនៅលើគេហទំព័រ https://covid19.ca.gov/industry-guidance/, កន្លែងទាំងនោះ ក៏ត្រូវគោរពតាមពិធីការសារមន្ទីរ, វិចិត្រសាល, មជ្ឈមណ្ឌលសហគមន៍, និងពិធីការអាងចិញ្ចឹមត្រីផងដែរ។ ពិធីការនេះត្រូវតែអនុវត្ត និងបិទផ្សាយនៅនឹងកន្លែង ឬគ្រឹះស្ថាន។ ការណែនាំនេះ មិនមានចេតនាអនុវត្តចំពោះការកំសាន្ត, សួនកំសាន្ត ឬឧទ្យានទឹកឡើយ។

សារមន្ទីរអាចត្រូវប្រតិបត្តិការ ខាងក្នុង នឹងខាងក្រៅ ។ចំណុះ ឬការកាន់កាប់នៅក្នុងសារៈមន្ទីរ ត្រូវតែកំណត់ត្រឹម ២៥% នៃការកាន់កាប់អតិបរមា។ មានការលើកទឹកចិត្តជាខ្លាំង អោយធ្វើប្រតិបត្តិការនៅខាងក្រៅ។ ក្រុមនានាដែលទៅទស្សនាសួនឧទ្យាន ត្រូវមានកំណត់ត្រឹម ១០ នាក់មកពីគ្រួសារផ្សេងៗគ្នា **ឬ** ចំនួនមនុស្សអតិបរមា ១៥ នាក់ នៃចំនួន ៣ គ្រួសារផ្សេងៗគ្នា ដែលមិនមានការលាយឡំជាមួយក្រុមផ្សេងណាមួយឡើយ (ឧទាហរណ៍ មនុស្សមិនអាចជំនួស ឬចេញពីក្រុមបានទេ)។

ប្រតិបត្តិការនៅខាងក្រៅអាចដំណើរការបាន ដោយយោងតាមការណែនាំរបស់ក្រសួងសុខាភិបាល រដ្ឋកាលីហ្វ័រញ៉ា ដែលមានចំណងជើងថា "ការប្រើប្រាស់រចនាសម្ព័ន្ធបណ្តោះអាសន្ន សំរាប់ប្រតិបត្តិការអាជីវកម្មនៅខាងក្រៅ" ដែលមាននៅទីនេះ https://www.cdph.ca.gov/Programs/CID/DCDC/Pages/COVID-19/Use-of-Temporary-Structures-for-Outdoor-Business-Operations.aspx.

លិខិតអនុញ្ញាតិណាមួយ ដែលបានចេញអោយដោយទីក្រុង ដែលតម្រូវអោយដំណើរការនៅខាងក្រៅ, រួមទាំងលិខិតអនុញ្ញាតិ ដែលតំរូវអោយតំឡើងតង់ណាមួយ, រានហាលជំរកព្រះអាទិត្យផ្សេងៗណាមួយ, ឬរចនាសម្ពន្ធ័ ដែលបានត្រូវប្រើប្រាស់ សំរាប់បរិភោគនៅខាងក្រៅ, ត្រូវតែទទួលបាននូវលិខិតអនុញ្ញាតិជាមុនសិន មុនពេលប្រតិបត្តិការ។

សារមន្ទីរ, វិចិត្រសាល, និងអាងចិញ្ចឹមត្រី ដែលមានសួនកំសាន្ត, កន្លែងលេង, ឬកន្លែងឡើង អាចបើកទីធ្លាលេងកំសាន្តខាងក្រៅ, កន្លែងលេងខាងក្រៅ, ឬកន្លែងឡើងខាងក្រៅ តាមការសំរេចចិត្តរបស់ប្រតិបត្តិករ និងស្របតាមការណែនាំរបស់រដ្ឋ ដែលមាននៅលើគេហទំព័រ mailto:https://www.cdph.ca.gov/Programs/CID/DCDC/Pages/COVID-19/Outdoor%20Playgrounds%20and%20other%20Outdoor%20Recreational%20Facilities.aspx. រាល់ទីធ្លាលេងកំសាន្តខាងក្នុង, កន្លែងលេង ឬកន្លែងឡើង គួរតែទុកតំបន់ទាំងនោះឱ្យនៅបិទ រហូតដល់ពួកគេ ត្រូវបានអនុញ្ញាតឱ្យដំណើរការ។

សារមន្ទីរដែលមានកន្លែងសន្និបាត, បន្ទប់ប្រជុំជួល, កន្លែងផ្សេងទៀត សម្រាប់ព្រឹត្តិការណ៍ឯកជននានា ។ល។ គួរតែទុកកន្លែងទាំងនោះឱ្យនៅបិទ រហូតដល់ការប្រមូលផ្តុំធំៗ ត្រូវបានអនុញ្ញាតិឱ្យបន្តប្រតិបត្តិការដែលបានកែប្រែផ្នែកខ្លះៗ ឬពេញលេញ តាមរយៈបទបញ្ជា និងការណែនាំអោយបើកដំណើរការឡើងវិញ ជាក់លាក់មួយ។ បញ្ឈប់ការបង្ហាញ, ដូចជាការបង្ហាញសត្វរស់, លើកលែងតែពិធីការឃ្លាតឆ្ងាយរាងកាយពីគ្នា និងពិធីការអនាម័យ ត្រូវបានធានា។

មានប្រសិទ្ធិភាពចាប់ពីថ្ងៃទី ១ ខែមេសា ឆ្នាំ ២០២១, ព្រឹត្តិការណ៍ផ្ទាល់នៅខាងក្រៅ (ឧទាហរណ៍ កីឡា និងការសម្តែងផ្ទាល់) អាចនឹងកើតឡើងស្របតាមតម្រូវការនានា នៅក្នុងផ្នែកនេះ និងការណែនាំណាមួយ ដែលតម្រូវដោយរដ្ឋ, ដែលមាននៅលើគេហទំព័រ https://covid19.ca.gov/industry-guidance/។ ចំណុះ ឬសមត្ថភាពក្នុងព្រឹត្តិការណ៍ផ្ទាល់ខាងក្រៅ ត្រូវបានកំណត់ត្រឹម ២០% នៃការកាន់កាប់អតិបរមា, ដោយរួមទាំងបន្ទប់ ដែលត្រូវបានកំណត់ត្រឹម ២៥% នៃការកាន់កាប់អតិបរមាក្នុងមួយបន្ទប់ ដែលមានចំនួនអតិបរមាចំនួន ១៥ នាក់ មិនអោយលើសពី ៣ គ្រួសារ ក្នុងមួយបន្ទប់។ ទីកន្លែងនោះត្រូវតែអនុវត្តកម្មវិធីធ្វើតេស្ត៍ ទៅលើកម្មករប្រចាំសប្តាហ៍ ស្របតាមការណែនាំរបស់រដ្ឋ។ ត្រូវកំណត់នូវការចូលរួមក្នុងព្រឹត្តិការណ៍ផ្ទាល់នៅខាងក្រៅសម្រាប់តែភ្ញៀវទេសចរក្នុងរដ្ឋ តែប៉ុណ្ណោះ។ នៅតែត្រូវបានហាមឃាត់ ចំពោះព្រឹត្តិការណ៍ផ្ទាល់នៅខាងក្នុង។

អាចនឹងរៀបចំនូវពិធីរៀបអាពាហ៍ពិពាហ៍ ឬពិធីបុណ្យសពនៅខាងក្រៅ ឬខាងក្នុង អនុលោមតាម "គោលការណ៍ណែនាំឧស្សាហកម្មជំងឺ COVID-19: កន្លែងគោរពបូជា និងអ្នកផ្តល់សេវាកម្មសាសនា និងពិធីបុណ្យវប្បធម៌" ដែលចែងថា៖(១) ត្រូវរក្សាអោយបានគ្រប់ពេលវេលាទាំងអស់នូវចំងាយរាងកាយចំនួន ៦ ហ្វីត រវាងមនុស្ស ឬក្រុមមនុស្សពីគ្រួសារផ្សេងៗគ្នា; (២) អ្នកចូលរួមប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់ នូវរាល់វិធានការណ៍ គំលាតរាងកាយពីគ្នា ឬគំលាតសង្គម ដែលបានបញ្ជាដោយការិយាល័យសុខភាពឡុងប៊ីជ, រួមទាំងការពាក់ម្របមុខលើមាត់ និងច្រមុះរបស់ពួគគេគ្រប់ពេលវេលាទាំងអស់; (៣) មិនមានបំរើនូវអាហារ, ភេសជ្ជៈ ឬភេសជ្ជៈមានជាតិអាល់កុលឡើយ; (៤) សមត្ថភាពខាងក្នុង ត្រូវតែបានកំណត់ត្រឹម ២៥% នៃការកាន់កាប់អតិបរមានៃទំហំខាងក្នុង។

រាល់ព្រឹត្តិការណ៍ ឬការជួបជុំធំៗផ្សេងៗទៀតទាំងអស់, ដូចជា ពិធីជប់លៀង/ព្រឹត្តិការណ៍ឯកជននានា ត្រូវតែលុបចោល ឬពន្យារពេលរហូតដល់មានការអនុញ្ញាតិដោយបទបញ្ញាស្នាក់នៅផ្ទះមានសុវត្ថិភាពជាងរបស់ក្រុងឡុងប៊ីជ។

- ❑ សារមន្ទីរដែលមានកន្លែងលក់រាយ ត្រូវតែគោរពតាម ពិធីការទិញទំនិញរាយដោយផ្ទាល់ (ឧបសម្ព័ន្ធ B)។
- ❑ ភោជនីយដ្ឋាន, ហាងកាហ្វេ និងជើងជំហ៊រលក់នៅក្នុងសារមន្ទីរ ត្រូវតែគោរពតាម ពិធីការភោជនីយដ្ឋានបរិភោគខាងក្នុង (ឧបសម្ព័ន្ធ H)។
- ❑ ទីធ្លាការិយាល័យនៅក្នុងសារមន្ទីរ ត្រូវតែគោរពតាម ពិធីការការិយាល័យការងារ (ឧបសម្ព័ន្ធទី G)។
- ❑ សេវាកម្មថែទាំរក្សា និងការពារ (ការណែនាំសំរាប់សេវាកម្ម CDPH ដែលមានកំណត់)
- ❑ កន្លែងលេងនៅខាងក្រៅ (ការណែនាំសំរាប់កន្លែងលេង CDPH នៅខាងក្រៅ)
- ❑ ការបាញ់ផ្កា ឬហ្គេមនានា (ការណែនាំសម្រាប់មជ្ឈមណ្ឌលកំសាន្តគ្រួសារ CDPH)
- ❑ មហោស្រព ឬរោងកុន (ការណែនាំសំរាប់រោងកុន CDPH)
- ❑ ព្រឹត្តិការណ៍ផ្ទាល់នៅខាងក្រៅ (ការណែនាំរបស់ CDPH; មានប្រសិទ្ធភាពចាប់ពីថ្ងៃទី ១ ខែមេសា ឆ្នាំ ២០២១)

សូមកត់សំគាល់៖ ឯកសារនេះអាចត្រូវបានធ្វើបច្ចុប្បន្នភាព នៅពេលដែលព័ត៌មាន និងធនធាននានាបន្ថែមទៀត អាចរកបាន ដូច្នេះត្រូវប្រាកដថា នឹងពិនិត្យមើលលើគេហទំព័រឡេងប៊ិច COVID-19 នៅឯ www.longbeach.gov/covid19 ជាប្រចាំ ដើម្បីទទួលបានព័ត៌មានថ្មីៗ ចំពោះឯកសារនេះ។

បញ្ជីផ្ទៀងផ្ទាត់នេះ រួមមាននូវ៖

(1) គោលនយោបាយនានា និងការអនុវត្តនៅកន្លែងធ្វើការ ដើម្បីការពារសុខភាពនិយោជិក
(2) វិធានការណ៍នានា ដើម្បីធានាបាននូវការឃ្លាតឆ្ងាយរាងកាយពីគ្នា
(3) វិធានការណ៍នានា ដើម្បីធានាការគ្រប់គ្រងការឆ្លង
(4) ការប្រាស្រ័យទាក់ទងជាមួយនិយោជិក និងសាធារណៈជន
(5) វិធានការណ៍នានា ដើម្បីធានាបាននូវការទទួលបាននូវសេវាកម្មចាំបាច់ ប្រកបដោយសមធម៌

ផ្នែកសំខាន់ៗទាំងប្រាំនេះ ត្រូវតែបានដោះស្រាយខណៈពេលដែលកន្លែងរបស់អ្នក អភិវឌ្ឍនូវពិធីការបើកឡើងវិញនោះ។

**អាជីវកម្មទាំងអស់ ដែលបានស្ថិតនៅក្នុងវិធានការណ៍ណែនាំខាងក្រោមនេះ ត្រូវត្រៀមជាស្រេច ដើម្បីពន្យល់ ថាតើហេតុអ្វីបានជាវិធានការណ៍ណាមួយ ដែលមិនបានត្រូវអនុវត្ត គឺមិនអាចអនុវត្តបាន ចំពោះអាជីវកម្ម។**

ឈ្មោះអាជីវកម្ម: ______________________

អាស័យដ្ឋានកន្លែង: ______________________

**ដើម្បីរាយការណ៍ការបំពាន**
**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**
**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**

## A. គោលនយោបាយកន្លែងធ្វើការ និងវិធានការណ៍នានា ដើម្បីការពារសុខភាពនិយោជិក (គួសទាំងអស់ដែលអាចអនុវត្តចំពោះទីកន្លែង)

- ❑ មនុស្សគ្រប់រូបដែលអាចបំពេញភារៈកិច្ចការងាររបស់ពួកគេពីផ្ទះ ត្រូវបានគេណែនាំអោយធ្វើដូច្នេះ។
- ❑ បុគ្គលិកដែលងាយរងគ្រោះ (អ្នកដែលមានអាយុលើសពី ៦៥ ឆ្នាំ, អ្នកដែលមានលក្ខ័ណ្ឌសុខភាពរ៉ាំរ៉ៃ) ត្រូវបានចាត់តាំងអោយធ្វើការដែលអាចធ្វើបានពីផ្ទះ នៅពេលណាដែលអាចធ្វើទៅបាន។
- ❑ ដំណើរការការងារត្រូវបានកំណត់ឡើងវិញ តាមលទ្ធភាពដែលអាចធ្វើទៅបាន ដើម្បីបង្កើនឱកាសសម្រាប់និយោជិកធ្វើការពីផ្ទះ។ ពិចារណាផ្តល់ជូនកម្មករ, មគ្គុទេសក៍, អ្នកហាត់ការ, និងបុគ្គលិកស្ម័គ្រចិត្ត ដែលស្នើសុំជម្រើសភារៈកិច្ច ដែលបានកែប្រែ ដែលកាត់បន្ថយនូវទំនាក់ទំនងរបស់ពួកគេ ជាមួយភ្ញៀវ និងនិយោជិកផ្សេងទៀត (ឧទាហរណ៍, ការគ្រប់គ្រងសារពើភ័ណ្ឌ ជាជាងធ្វើការជាអ្នកគិតលុយ ឬគ្រប់គ្រងតម្រូវការរដ្ឋបាល តាមរយៈទូរគមនាគមន៍)។
- ❑ កាលវិភាគឆ្លាស់គ្នា, បន្តរបន្ទាប់គ្នា ឬប្តូរវេន ត្រូវបានបង្កើតឡើង ដើម្បីពង្រីកគំលាតឆ្ងាយរាងកាយពីគ្នា។
- ❑ និយោជិកទាំងអស់ (រាប់បញ្ចូលទាំងបុគ្គលិកដែលទទួលបានប្រាក់ឈ្នួល, មគ្គុទេសក៍, អ្នកហាត់ការ, និងអ្នកស្ម័គ្រចិត្ត; ដែលត្រូវបានសំដៅជាសមូហភាព ថាជា "និយោជិក") ត្រូវបានគេប្រាប់ថា មិនឱ្យមកធ្វើការប្រសិនបើឈឺ ឬប្រសិនបើពួកគេត្រូវបានប៉ះពាល់ នឹងអ្នកដែលមានជំងឺ COVID-19។ និយោជិក យល់ថាត្រូវធ្វើតាមបទបញ្ជារបស់មន្ត្រីសុខភាពទីក្រុងឡុងប៊ីឆ សំរាប់ការដាក់ខ្លួនអោយនៅឯកោ និង ការដាក់ខ្លួនអោយនៅឃ្លាតឆ្ងាយពីអ្នកដ៏ទៃ, ប្រសិនបើអាចធ្វើទៅបាន។ គោលនយោបាយឈប់សម្រាក នៅកន្លែងធ្វើការត្រូវបានពិនិត្យ និងកែប្រែ ដើម្បីធានាថាអ្នកធ្វើការមិនត្រូវបានពិន័យ នៅពេលពួកគេស្នាក់នៅផ្ទះដោយសារជំងឺនោះឡើយ។
    - ○ ព័ត៌មានអំពីអត្ថប្រយោជន៍ នៃការឈប់សម្រាកដែលឧបត្ថម្ភដោយនិយោជក ឬរដ្ឋាភិបាល ដែលនយោជិក អាចមានសិទ្ធិទទួលបាន ដែលនឹងធ្វើឱ្យវាកាន់តែមានភាពងាយស្រួលខាងផ្នែកហិរញ្ញវត្ថុ ក្នុងពេលស្នាក់នៅផ្ទះ។ សូមមើលព័ត៌មានបន្ថែម ស្តីពីកម្មវិធីរបស់រដ្ឋាភិបាល ដែលគាំទ្រការឈប់សម្រាកឈឺ និងសំណងរបស់កម្មករសម្រាប់ជំងឺ COVID19, រួមមានសិទ្ធិឈប់សម្រាកឈឺរបស់និយោជិក ក្រោមច្បាប់ឆ្លើយតប ជំងឺខូរ៉ូណាវីរ៉ុស គ្រួសារជាចំបង និងសិទ្ធិរបស់និយោជិក ចំពោះអត្ថប្រយោជន៍សំណងរបស់កម្មករ និងការសន្មតថា ការងារដែលជាប់ទាក់ទងនឹងជំងឺ COVID-19 ដោយអនុលោមតាមបទបញ្ជាប្រតិប័ត្តរបស់អភិបាលរដ្ឋ លេខ N-62-20។

- ❑ នៅពេលទទួលបានដំណឹងថានិយោជិកម្នាក់ ឬច្រើននាក់ ធ្វើតេស្តិ៍វិជ្ជមាន, ឬមានរោគសញ្ញាស្របគ្នាទៅនឹងជំងឺ COVID-19 (ករណី), និយោជកត្រូវមានផែនការ ឬពិធីសារដើម្បីអោយករណីដាក់ខ្លួនគេអោយនៅឯកោនៅផ្ទះ ហើយតម្រូវអោយមានការដាក់អោយនៅឃ្លាតដាច់ឆ្ងាយពីគេខ្លួនឯងភ្លាមៗចំពោះ ឬនៃនិយោជិកទាំងអស់ ដែលមានការប្រឈមនៅនឹងកន្លែងធ្វើការ ទៅនឹងករណី។ ផែនការរបស់និយោជក គួរតែពិចារណាលើពិធីការសម្រាប់និយោជិកដែលបានដាក់ខ្លួនអោយនៅឃ្លាតដាច់ឆ្ងាយពី គេទាំងអស់មានលទ្ធភាពធ្វើតេស្ត ឬត្រូវបានធ្វើតេស្ត សំរាប់ជំងឺ COVID-19 ដើម្បីកំណត់ថា តើមានការប្រឈមនៅកន្លែងធ្វើ ការបន្ថែមទៀត, ដែលអាចតម្រូវឱ្យមានវិធានការណ៍ត្រួតពិនិត្យជំងឺ COVID-19 បន្ថែម។

**ដើម្បីរាយការណ៍ការបំពាន**
**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**
**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**

- ❑ ការត្រួតពិនិត្យរោគសញ្ញា ត្រូវបានធ្វើឡើងមុនពេលនិយោជិកអាចចូលធ្វើការ។ ការត្រួតពិនិត្យត្រូវ តែរាប់បញ្ចូលទាំងការសួរនាំ ឬផែកឆេរទាក់ទងទៅនឹងការក្អក, ដង្ហើមខ្លី/ដង្ហក់ ឬគ្រុនក្តៅ និងរោគសញ្ញាផ្សេងទៀត ដែលបុគ្គលិកអាចនឹងកំពុងជួបប្រទះ។ ការត្រួតពិនិត្យទាំងនេះ អាចត្រូវបានធ្វើឡើងពីចម្ងាយ ឬដោយផ្ទាល់ នៅពេលមកដល់របស់និយោជិក។
- ❑ ការត្រួតពិនិត្យសីតុណ្ហភាព គួរតែត្រូវបានធ្វើនៅកន្លែងធ្វើការ ប្រសិនបើអាចធ្វើទៅបាន។
- ❑ ក្នុងករណីដែលមានករណីចំនួន ៣ ឬច្រើនជាងនេះ ត្រូវបានរកឃើញនៅក្នុងកន្លែងធ្វើការក្នុងរយៈពេល ១៤ ថ្ងៃ និយោជកគួរតែរាយការណ៍ពីចង្កោមហេតុការណ៍នេះ ទៅមន្ទីរសុខាភិបាល និងសេវាមនុស្សនៃទីក្រុងឡុងប៊ិច តាមលេខ ៥៦២-៥៧0-INFO
- ❑ និយោជិកទាំងអស់ដែលមានទំនាក់ទំនងជាមួយសាធារណៈជន ឬនិយោជិកផ្សេងទៀត ក្នុងកំឡុងវេនរបស់ពួកគេ ត្រូវបានផ្តល់ជូន, ដោយឥតគិតថ្លៃ, នូវ គម្របមុខ។ និយោជិតត្រូវពាក់គម្របមុខ គ្រប់ពេលវេលាទាំងអស់ នៅក្នុងកំឡុងពេលថ្ងៃធ្វើការ លើកលែងតែបុគ្គលិកនោះធ្វើការក្នុងរថយន្ត, ការិយាល័យ, ឬនៅក្នុងបន្ទប់តែម្នាក់ឯង។ និយោជិកនានា ដែលត្រូវបានណែនាំដោយអ្នកផ្តល់សេវាវេជ្ជសាស្ត្ររបស់ពួកគេ ថាពួកគេមិនគួរពាក់គម្របមុខ គួរតែពាក់ខែលការពារមុខ ជាមួយ ឬដោយប្រើក្រវ៉ាត់នៅលើគែមខាងក្រោម, អោយត្រូវនឹងសេចក្តីណែនាំរបស់រដ្ឋ, ដរាបណាលក្ខ័ណ្ឌរបស់ពួកគេអនុញ្ញាតិអោយ។ មានការណែនាំអោយប្រើក្រវ៉ាត់ ដែលត្រូវបានបង្កើតជាទម្រង់សមក្លឹបល្មម នៅក្រោមចង្កា ។ ម៉ាស់ដែលមានវ៉ាល់មួយផ្លូវ មិនគួរត្រូវបានប្រើឡើយ។
- ❑ អនុវត្តនូវការធ្វើការងារ ដើម្បីកំណត់ចំនួនកម្មករនៅក្នុងកន្លែងធ្វើការរួមគ្នា ក្នុងពេលតែមួយ។
- ❑ រៀបចំកំណត់ឡើងវិញនូវកន្លែងការិយាល័យ, ស្ថានីយ៍ធ្វើការ, បញ្ជរគិតលុយ/ឆែកចេញ; ជាដើម។ល។ ដើម្បីអនុញ្ញាតឱ្យមានគំលាតឆ្ងាយរាងកាយពីគ្នា យ៉ាងតិច ៦ ហ្វីត ពីកម្មករម្នាក់ទៅកម្មករម្នាក់ទៀត។
- ❑ ជៀសវាងការចែករំលែករថយន្ត នៅពេលធ្វើដំណើរក្នុងទ្រព្យសម្បត្តិ។
- ❑ និយោជិក ត្រូវបានណែនាំឱ្យលាងសំអាតគម្របមុខរាល់ថ្ងៃ។
- ❑ និយោជិកត្រូវបានគេផ្តល់ស្រោមដៃអោយផងដែរ សម្រាប់ភារៈកិច្ចដែលតម្រូវឱ្យពួកគេធ្វើការ ទៅលើផ្ទៃដែលប៉ះពាល់ញឹកញាប់ ឬសម្រាប់ប្រើក្នុងកំឡុងពេលពិនិត្យរោគសញ្ញា។
- ❑ ពិចារណាអំពីការប្រើប្រាស់នូវកញ្ចក់របាំងបែងចែកប្លាស្ទិច នៅក្នុងតំបន់ដែលនិយោជិកត្រូវធ្វើអន្តរៈកម្ម ជាមួយអតិថិជន ដូចជាបញ្ជរទូទាត់ ឬមជ្ឈមណ្ឌលព័ត៌មាន។
- ❑ ស្ថានីយ៍ធ្វើការរបស់និយោជិកនៅតាមតំបន់នានា ដូចជាបញ្ជរសំបុត្រ ឬបញ្ជរព័ត៌មាន ត្រូវបានបំបែក ដោយយ៉ាងហោច ណាស់ ៦ ហ្វីត និងតំបន់រួម ត្រូវបានរៀបចំ ដើម្បីធានាបាននូវការឃ្លាតឆ្ងាយរាងកាយពីគ្នា យ៉ាងហោចណាស់ ៦ ហ្វីត។
- ❑ និយោជិកត្រូវបានណែនាំអោយរក្សាចម្ងាយយ៉ាងតិចប្រាំមួយ (៦) ហ្វីត ពីអតិថិជន និងពីគ្នាទៅវិញទៅមក។ និយោជិក អាចចូលមកជិតមួយភ្លែត នៅពេលមានការចាំបាច់ ដើម្បីទទួលយកការទូទាត់, ប្រគល់ទំនិញ ឬសេវាកម្ម ឬតាមការចាំបាច់ នានា។

**ដើម្បីរាយការណ៍ការបំពាន**
**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**
**អ៊ីមែល: CETASKFORCE@LONGBEACH.GOV**

- ❑ បន្ទប់សំរាក, បន្ទប់ទឹក និងកន្លែងទូទៅផ្សេងទៀត កំពុងត្រូវបានគេសំឡាប់មេរោគជាញឹកញាប់, តាមកាលវិភាគដូចខាង ក្រោមៈ
  - ○ បន្ទប់សំរាក ______________________
  - ○ បន្ទប់ទឹក ______________________
  - ○ ផ្សេងៗ ______________________
- ❑ ការសម្រាកត្រូវបានធ្វើឱ្យបណ្តាក់វេនគ្នា ដើម្បីធានាអោយបាននូវចំងាយ ប្រាំមួយ (6) ហ្វីត រវាងបុគ្គលិក ដែលអាចត្រូវបានរក្សា នៅក្នុងតំបន់សម្រាក ឬបន្ទប់សម្រាក ត្រូវបានកំណត់រៀបចំឡើងវិញ ឬបិទ ដោយមានកន្លែងជំនួសដែលត្រូវបានបង្កើតឡើង សម្រាប់ការសំរាក ដើម្បីអោយមានការនៅឃ្លាតឆ្ងាយពីគ្នា ប្រសិនបើអាចធ្វើទៅបាន។
- ❑ ថ្នាំសំឡាប់មេរោគ និងគ្រឿងផ្គត់ផ្គង់នានា សំរាប់និយោជិកទាំងអស់ អាចរកបានតាមទីតាំងនានា ដូចខាងក្រោមៈ

  ______________________
- ❑ ទឹកលាងដៃសំឡាប់មេរោគមានប្រសិទ្ធិភាពប្រឆាំងជំងឺ COVID-19 សំរាប់និយោជិកទាំងអស់ អាចរកបានតាម ទីតាំងនានា ដូចខាងក្រោមៈ

  ______________________
- ❑ និយោជិកត្រូវបានតំរូវអោយ និងអនុញ្ញាតិអោយមានពេលវេលាគ្រប់គ្រាន់ សម្រាប់លាងដៃរបស់ពួកគេ យ៉ាងហោចណាស់រៀងរាល់ ៣០ នាទីម្តង ឬនៅពេលដែលមានតំរូវការ ប្រសិនបើស្រោមដៃបានត្រូវផ្តល់អោយ។ នៅកន្លែង ដែលការលាងដៃ គឺមិនអាចអនុវត្តបាន, ទឹកធ្វើអនាម័យដៃ ដែលមានជាតិអាល់កុលយ៉ាងហោចណាស់ ៦០% ត្រូវបានផ្តល់ទៅដល់និយោជិកជំនួសវិញ។
- ❑ ច្បាប់ចតចំលងនៃពិធីការនេះ ត្រូវបានចែកចាយដល់និយោជិកនីមួយៗ។
- ❑ កម្មករម្នាក់ៗត្រូវបានចាត់តាំងអោយនូវឧបករណ៍, សំភារៈ និងទីកន្លែងធ្វើការងារផ្ទាល់ខ្លួនរបស់ពួកគេ។ និយោជិកទាំងឡាយ ត្រូវបានគេណែនាំអោយ ជៀសវាងការចែករំលែកទូរស័ព្ទ, កុំព្យូទ័របន្ទះ ឬថេប្លេត, វិទ្យុពីរផ្លូវ, ឧបករណ៍ការងារផ្សេងៗ ទៀត, ឬឧបករណ៍ការិយាល័យ នៅពេលណាដែលអាចធ្វើទៅបាន។ ផងដែរ ពួកគេក៏ត្រូវបានណែនាំ មិនអោយចែករំលែក PPE ឡើយ។
- ❑ នៅកន្លែងដែលត្រូវចែករំលែករបស់របរនានា, ពួកគេត្រូវបានសំឡាប់មេរោគជាមួយឧបករណ៍សម្អាតដែលសមស្របសម្រាប់ផ្ទៃរវាងការផ្លាស់ប្តូរវេន ឬការប្រើប្រាស់ណាមួយ ដែលញឹកញាប់ខ្លាំង, រួមបញ្ចូលនូវឧបករណ៍ដូចខាងក្រោមនេះៈ ឧបករណ៍ការិយាល័យរួម, ដូចជាម៉ាស៊ីនថតចំលង, ម៉ាស៊ីនទូរសារ, ម៉ាស៊ីនព្រីនធ័រ, ក្តារចុច, ប្រដាប់កឹប, ប្រដាប់ដកគ្រាប់កឹប, ប្រដាប់បើកសំបុត្រ, ផ្ទៃនៅលើកន្លែងទទួលភ្ញៀវ, ស្ថានីយ៍ការងាររួម, ឧបករណ៍អូឌីយ៉ូស្តាប់ និងវីដេអូ, ឧបករណ៍ជជែកគ្នា ឬអេកូម ។ល។
- ❑ ពេលវេលាត្រូវបានផ្តល់ជូននិយោជិក ដើម្បីអនុវត្តនូវការអនុវត្តនូវការសំអាត ក្នុងអំឡុងពេលវេនរបស់ពួកគេ។ ការងារសំអាត ត្រូវបានផ្តល់ឱ្យក្នុងម៉ោងធ្វើការ ដែលជាផ្នែកមួយនៃភារៈកិច្ចការងាររបស់និយោជិក។ កែប្រែម៉ោង, ប្រសិនបើចាំ បាច់, ដើម្បីធានាអោយបាននូវការសម្អាតឱ្យបានទៀងទាត់ និងហ្មត់ចត់តាមភាពសមរម្យ។ ជម្រើសអោយមាន នូវលទ្ធ កម្មសម្រាប់ក្រុមហ៊ុន

សំអាតនៃភាគីទីបី ដើម្បីជួយដល់តម្រូវការសំអាតដែលបានកើនឡើង, ទៅតាមតម្រូវការ។

- ❑ គោលនយោបាយទាំងអស់ ដែលបានពិពណ៌នានៅក្នុងបញ្ជីត្រួតពិនិត្យនេះ ក្រៅពីគោលការណ៍ទាក់ទងនឹងលក្ខ័ណ្ឌនៃការងារ ត្រូវបានអនុវត្តចំពោះបុគ្គលិកនៃការចែកចាយ ឬបញ្ជូន និងក្រុមហ៊ុនផ្សេងណាមួយទៀត ដែលអាចមាននៅក្នុងបរិវេណ ជាភាគីទីបី។
- ❑ ស្រេចលើចិត្ត — ពិពណ៌នាពីវិធានការណ៍ផ្សេងទៀត:

____________________________________________________________________

## B. វិធានការណ៍នានា ដើម្បីធានាបាននូវគំលាតឆ្ងាយរាងកាយពីគ្នា

- ❑ ចំនួនមនុស្សនៅខាងក្នុង នឹងខាងក្រៅកន្លែងសារៈមន្ទីរមានកំរិតទាបគ្រប់គ្រាន់ ដើម្បីធានាអោយមានការរក្សាគំលាតរាងកាយពីគ្នា យ៉ាងតិច ៦ ហ្វីត ប៉ុន្តែក្នុងករណីណាក៏ដោយ មិនអោយលើសពី ២៥% នៃចំណុះ ឬការកាន់កាប់អតិបរិមា នៃសារៈមន្ទីរឡើយ។

  ចំនួនមនុស្សអតិបរមា នៅខាងក្នុងសារៈមន្ទីរ ត្រូវបានកំណត់ត្រឹម: ________________

- ❑ ច្រកចូលសារមន្ទីរ ឬកន្លែងវិចិត្រសាល ត្រូវបានកំរឹតដើម្បីធានាឱ្យមានគំលាតឆ្ងាយរាងកាយពីគ្នា យ៉ាងហោចណាស់ ៦ ហ្វីតដោយភ្ញៀវទេសចរណ៍ ឬអ្នកទស្សនា និងចាត់តាំងរៀបចំនូវជម្រើសនានា ដូចជាកំរឹតនូវសំបុត្រចូលតាមពេលវេលា ដើម្បីធានាបាននូវគំលាតឆ្ងាយរាងកាយពីគ្នា។ ក្រុមនានាដែលទៅទស្សនាសារៈមន្ទីរ ត្រូវមានកំណត់ត្រឹម ១០ នាក់ ឬរហូតដល់ ៣ គ្រួសារ និងចំនួនមនុស្សអតិបរមា ១៥ នាក់ ដែលមិនមានការលាយឡំជាមួយក្រុមផ្សេងណាមួយឡើយ (ឧទាហរណ៍ មនុស្សមិនអាចជំនួស ឬចេញពីក្រុមបានទេ)។ គ្រឹះស្ថានត្រូវត្រួតពិនិត្យនៅតាមច្រកចេញទាំងអស់ ដើម្បីតាមដានទៅលើចំណុះ ឬការកាន់កាប់នៅក្នុងអាគារ។ នៅកន្លែងដែលអាចធ្វើបាន, ផ្តល់ច្រកចូលតែមួយដែលត្រូវបានកំណត់បង្ហាញអោយបានច្បាស់ណាស់ និងច្រកចេញដាច់ដោយឡែក ដើម្បីជួយរក្សាគំលាតឆ្ងាយរាងកាយពីគ្នា។
- ❑ ត្រៀមខ្លួនរួចជាស្រេច ក្នុងការរៀបតម្រង់ជួរអតិថិជននៅខាងក្រៅ ដោយក្នុងនោះ នៅតែរក្សាគំលាតឆ្ងាយរាងកាយពីគ្នា, ដោយរួមទាំង ការដាក់តាំងសញ្ញានានាអោយមើលឃើញ។ ប្រសិនបើចាំបាច់, និយោជិកម្នាក់ (ឬនិយោជិកច្រើននាក់ ប្រសិនបើមានច្រកចូលច្រើនជាងមួយ) ដាក់តាំង ឬបិទផ្លាកសញ្ញាអំពីការពាក់នូវគម្របមុខក្រណាត់ នៅជិតច្រកចូល ដែលផ្លាកនោះ មានចម្ងាយយ៉ាងតិច ៦ ហ្វីត ពីអតិថិជនដែលនៅជិតបំផុត ដើម្បីធ្វើការតាមដានទៅលើចំណុះ និងណែនាំអតិថិជនឱ្យតម្រង់ជួរគ្នា ចម្ងាយ ៦ ហ្វីតពីគ្នា នៅខាងក្រៅច្រកចូល ប្រសិនបើគ្រឹះស្ថានបានឈានដល់កំរិតចំណុះ/ការកាន់កាប់គ្រប់ចំនួនរបស់ខ្លួនហើយនោះ។
- ❑ ចាត់បុគ្គលិកមួយរូប អោយធ្វើការណែនាំភ្ញៀវនៅតំបន់ចរាចរណ៍ខ្ពស់ ដើម្បីការពារនូវការប្រមូលផ្តុំ។
- ❑ ដំណើរកម្សាន្តដែលរួមបញ្ចូលគ្នានូវបុគ្គលមកពីក្រុមនានា ត្រូវបានបញ្ឈប់ ហើយមគ្គុទេសទេសចរណ៍ រក្សានូវចម្ងាយ ៦ ហ្វីត ពីក្រុមដំណើរកម្សាន្ត។

**ដើម្បីរាយការណ៍ការបំពាន**
**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**
**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**

- ❑ ការឃ្លាតឆ្ងាយរាងកាយពីគ្នា ត្រូវបានអនុវត្តនៅគ្រប់ទីកន្លែងតាំងពិព័រណ៌ទាំងអស់ ដែលមានសញ្ញាសំគាល់ដែលដាក់នៅជុំវិញការបង្ហាញ/ការដាក់តាំង ដើម្បីបង្ហាញកន្លែងដែលភ្ញៀវទេសចរណ៍ត្រូវឈរ ដើម្បីមើលការបង្ហាញ។ ប្រសិនបើអាចធ្វើទៅបាន, ញែកផ្លូវដាច់ដោយឡែក សម្រាប់ការចូល និងចេញ តាមរយៈការតាំងពិព័រណ៍, វិចិត្រសាល, កន្លែងទស្សនា និងកន្លែងធ្វើការរបស់និយោជិក ត្រូវបានបង្កើតឡើង ដើម្បីជួយរក្សាគំលាតឆ្ងាយរាងកាយពីគ្នា និងកាត់បន្ថយនូវការដែលមនុស្សឆ្លងកាត់គ្នាយ៉ាងជិតស្និទ្ធ។ ផ្លូវដើរដែលមានទិសដៅតែមួយ, ផ្លូវឆ្លងកាត់, ។ល។ សម្រាប់ចរាចរណ៍ជើង ត្រូវបានបង្កើតឡើង ដើម្បីកាត់បន្ថយលំហូរប្រជាជនឆ្លងកាត់ទៅវិញទៅមកនៅក្នុងកន្លែង ឬគ្រឹះស្ថាន។
- ❑ ចំនួនអ្នកទេសចរណ៍ទៅកន្លែងតាំងពិព័រណ៌តូច នៅក្នុងសារមន្ទីរ ត្រូវបានដាក់កម្រិតនៅពេលណាមួយ, ដើម្បីបន្តរក្សាចម្ងាយ ៦ ហ្វីតរវាងឯកត្តបុគ្គល ឬ ក្រុមខុសៗគ្នាផ្សេងៗ។ ច្រកចូលទាំងអស់នៅតំបន់ទាំងនេះ ត្រូវតែត្រួតពិនិត្យ ដើម្បីតាមដានចំនួនភ្ញៀវទេសចរណ៍ ដែលចូលក្នុងកន្លែងនោះ។
  - ○ បុគ្គលិកម្នាក់ (ឬបុគ្គលិក ប្រសិនបើមានច្រកចូលច្រើនជាងមួយ) ពាក់គម្របមុខក្រណាត់ ត្រូវបានបិទនៅជិតច្រកចូលកន្លែងដាក់តាំងពិព័រណ៌ ប៉ុន្តែមានចម្ងាយយ៉ាងតិច ៦ ហ្វីត ពីអ្នកទេសចរដែលនៅជិតបំផុត ដើម្បីតាមដានការកាន់កាប់ និងភ្ញៀវដោយផ្ទាល់ ដើម្បីតម្រង់ជួរ ឆ្ងាយពីគ្នាចម្ងាយ ៦ ហ្វីត ប្រសិនបើចន្លោះបានដល់កំរិត នៃការកាន់កាប់របស់វា។
- ❑ អនុវត្តប្រព័ន្ធកំណត់ពេលវេលា និង/ឬកក់សំបុត្រទុកជាមុន ដើម្បីរៀបចំភ្ញៀវធ្វើការទស្សនាបន្តរបន្ទាប់គ្នា។
- ❑ និយោជិក និងអ្នកទេសចរត្រូវបានលើកទឹកចិត្តពីការប្រមូលផ្តុំគ្នា នៅតំបន់ដែលមានចរាចរណ៍ខ្ពស់ ដូចជាបន្ទប់ទឹក និងតាមផ្លូវដើរ។
- ❑ រៀបចំកន្លែងអង្គុយឡើងវិញ និង/ឬដកកៅអីចេញ ដើម្បីអនុញ្ញាតឱ្យមានគំលាតឆ្ងាយរាងកាយពីគ្នា យ៉ាងតិចបំផុតចំនួនប្រាំមួយហ្វីត រវាងអតិថិជន/ភ្ញៀវ។ បិទឬដាក់ស្លាកសញ្ញានៅកន្លែងអង្គុយចែករំលែក, កន្លែងអង្គុយដែលមិនអាចរំកិល ឬដូរកន្លែងបាន (កៅអីវែង ។ល។) ដើម្បីរំលឹកដល់អតិថិជន/ទេសចរណ៍ឲ្យឃ្លាតឆ្ងាយរាងកាយពីអ្នកដទៃ នៅខាងក្រៅពិធីជប់លៀងរបស់ពួកគេ។
- ❑ តំបន់ដែលត្រូវបានប្រើសម្រាប់ការបង្ហាញផ្ទាល់ការបង្ហាញសត្វជាដើមត្រូវបានកំណត់រចនាសម្ព័ន្ធឡើងវិញដើម្បីឱ្យមានភាពខុសគ្នារវាងរាងកាយនិងក្រុមនានា ។ពិចារណាអនុវត្តការកក់កម្រិតខ្ពស់សម្រាប់ការធ្វើបាតុកម្មនិងឱ្យបុគ្គលិកធ្វើការនាំក្រុមនានា ទៅកន្លែងមើលឱ្យបានត្រឹមត្រូវ។
- ❑ គ្រឹះស្ថាន ឬកន្លែងកំណត់សេវាកម្មដឹកជញ្ជូនមកទំលាក់ នៅពេលណាដែលអាចធ្វើទៅបាន និងអនុលោមទៅតាមកាតព្វកិច្ចចំពោះជនពិការ។ និយោជិកចៀសវាងចែករំលែកយានយន្ត នៅពេលធ្វើដំណើរលើអចលទ្រព្យ។ នៅពេលដែលនិយោជិក ឬអតិថិជន/ ភ្ញៀវទេសចរណ៍ត្រូវតែធ្វើដំណើរជាមួយគ្នា ការប្រើគម្របមុខត្រូវបានទាមទារ។
- ❑ សមាជិកនៃក្រុមគ្រួសារ ឬយូនីតរស់នៅតែមួយ មិនចាំបាច់ស្ថិតនៅឆ្ងាយពីគ្នាចំងាយ ៦ ហ្វីត ឡើយ។
- ❑ ផ្លូវដើរ និងផ្លូវថ្មើរជើង ត្រូវបានបង្កើតឡើងដោយមានស្តុប ឬសញ្ញាសម្គាល់ដើម្បីបង្កើតលំហូរផ្លូវមួយ ដោយថ្មើជើង តែមួយទិសដៅ។
- ❑ កន្លែងអង្គុយសាធារណៈ ត្រូវបានរៀបចំ ឬកំណត់រចនាសម្ព័ន្ធឡើងវិញ ដើម្បីគាំទ្រដល់ការឃ្លាតឆ្ងាយរាងកាយពីគ្នា រវាងអតិថិ

**ដើម្បីរាយការណ៍ការបំពាន**
**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**
**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**

ជន និងភ្ញៀវ។

- ❑ បន្ទប់ទឹករបស់និយោជិក មិនមានសម្រាប់ការប្រើប្រាស់របស់អតិថិជនឡើយ។
- ❑ ទីធ្លាលេងកំសាន្តខាងក្នុង, រចនាសម្ព័ន្ធនានាសំរាប់ឡើង, និងកន្លែងលេងនានា នៅតែបិទ។ ទីធ្លាលេងកំសាន្តខាងក្រៅ, រចនាសម្ព័ន្ធសំរាប់ឡើង, និងទីធ្លាលេង អាចបើក តាមការសំរេចចិត្តរបស់ប្រតិបត្តិករ និងស្របតាមការណែនាំរបស់រដ្ឋ ដែលមាននៅលើគេហទំព័រ at https://www.cdph.ca.gov/Programs/CID/DCDC/Pages/COVID-19/Outdoor%20Playgrounds%20and%20other%20Outdoor%20Recreational%20Facilities.aspx.

## C. វិធានការណ៍នានា សំរាប់ការគ្រប់គ្រងការឆ្លង

- ❑ ប្រព័ន្ធទូទាត់ប្រាក់ដែលមិនចាំបាច់ប៉ះ ត្រូវបានដាក់ឱ្យដំណើរការ ឬ, ប្រសិនបើមិនអាចធ្វើទៅបានទេ, ប្រព័ន្ធទូទាត់ត្រូវបានធ្វើអនាម័យជាប្រចាំ។ ពិពណ៌នា៖

---

- ❑ តំបន់ទូទៅ និងវត្ថុដែលត្រូវប៉ះពាល់ញឹកញាប់ (ឧទាហរណ៍, ប្រដាប់មូល ឬដៃទ្វា, ម៉ាស៊ីនអានក្រេឌីតកាត, ឧបករណ៍ប្តូរពន្លឺ, រនុកកាន់, បង្កាន់ដៃ, ផ្លាកប្រកាសផ្សាយនានា, ។ល។) ត្រូវបានរំងាប់មេរោគ ក្នុងរយៈពេលមួយម៉ោងម្តង ក្នុងអំឡុងម៉ោងធ្វើការ ដោយប្រើឧបករណ៍រំងាប់មេរោគ ដែលត្រូវបានអនុម័តដោយ EPA និងអនុវត្តតាមការណែនាំរបស់អ្នកផលិត សម្រាប់ការប្រើប្រាស់។ ប្រតិបត្តិករកំណត់ និងរំងាប់មេរោគលើផ្ទៃ ដែលកុមារទំនងជានឹងប៉ះ, ដូចជាផ្នែកនៃបង្អួច, ពិព័រណ៍, ឬបង្គោលរបងដែលដាក់នៅជិតដី។
- ❑ សម្អាតឱ្យបានហ្មត់ចត់នូវតំបន់ ណា ដែលនិយោជិក ឬសាធារណៈជនប្រើប្រាស់ ឬកាន់កាប់ដើម្បីរក្សាប្រតិបត្តិការ នៃពិព័រណ៍ ទាំងអស់ ត្រូវបានអនុវត្តជារៀងរាល់ថ្ងៃ។ នេះគួរតែរួមបញ្ចូលទាំង តំបន់ចរាចរណ៍ខ្ពស់ និងកន្លែងធ្វើការរួមគ្នា (ការិយាល័យ, បន្ទប់ប្រជុំ, បន្ទប់សម្រាក។ ល។), និងតំបន់ចេញចូលនានាទាំងអស់ (បង្កាន់ដៃ, ដៃជណ្តើរ, ប្រដាប់បញ្ជាជណ្តើរយន្ត។ ល។)
- ❑ ភ្ញៀវទេសចរណ៍ ឬអ្នកទស្សនាត្រូវបានលើកទឹកចិត្តឱ្យទិញថ្លៃចូលជាមុន តាមអ៊ិនធរណេត។ ប្រសិនបើអាចធ្វើទៅបាន, សំបុត្រគឺឌីជីថលដែលមានលេខកូដ QR ដើម្បីអនុញ្ញាតឱ្យមានប្រព័ន្ធគ្មានក្រដាស និងគ្មានការប៉ះ។
- ❑ តាមលទ្ធភាពដែលអាចធ្វើទៅបាន, អ្នកទេសចរណ៍ចូលទស្សនាសារមន្ទីរ ត្រូវបានចុះឈ្មោះនៅក្នុងបញ្ជីឈ្មោះភ្ញៀវ ដែលរួមមានឈ្មោះរបស់អ្នកទេសចរណ៍, លេខទូរស័ព្ទ និងអាស័យដ្ឋានអ៊ីម៉ែល ដែលអាចធ្វើបាន នៅពេលទិញសំបុត្រ ឬចុះឈ្មោះ។
- ❑ កន្លែងទាំងមូល ត្រូវបានសម្អាតយ៉ាងហោចណាស់ជារៀងរាល់ថ្ងៃ, ដោយមានបន្ទប់ទឹក និងកន្លែងដែលបានប៉ះពាល់/វត្ថុ ដែលត្រូវបានសម្អាតញឹកញាប់អោយបានច្រើន អាស្រ័យលើភាពញឹកញាប់នៃការប្រើប្រាស់។ ផ្ទៃទាំងឡាយ ធ្វើពីផ្លាស្ទិច ឬដែក ក៏ត្រូវបានសម្អាតផងដែរ។ កុំបាញ់ថ្នាំរំងាប់មេរោគ ពីលើផ្ទៃឈើ, ឬចិញ្ចើមផ្លូវ។
- ❑ បន្ទប់ទឹកសាធារណៈ ត្រូវបានគេធ្វើអនាម័យជាប្រចាំ ដោយប្រើឧបករណ៍រំងាប់មេរោគ ដែលត្រូវបានអនុម័

តដោយ EPA។ តាមកាលវិភាគ ដូចខាងក្រោមៈ

---

- ☐ ការត្រួតពិនិត្យរោគសញ្ញា ត្រូវបានធ្វើឡើងមុនពេលភ្ញៀវទេសចរណ៍អាចចូលក្នុងកន្លែង ឬគ្រឹះស្ថាន។ ការត្រួតពិនិត្យត្រូវតែរាប់បញ្ចូលទាំងការឆែកឆេរ ឬពិនិត្យទាក់ទងទៅនឹងការក្អក, ដង្ហើមខ្លី ឬគ្រុនក្តៅ និងរោគសញ្ញាផ្សេងទៀត ដែលភ្ញៀវទេសចរណ៍អាចនឹងកំពុងជួបប្រទះ។ ការត្រួតពិនិត្យទាំងនេះ អាចត្រូវបានធ្វើឡើងពីចម្ងាយ ឬដោយផ្ទាល់នៅពេលការមកដល់ របស់ភ្ញៀវទេសចរណ៍។
- ☐ ភ្ញៀវដែលមកដល់កន្លែង ឬគ្រឹះស្ថាន ត្រូវបានស្នើសុំឱ្យប្រើទឹកធ្វើអនាម័យដៃ ហើយត្រូវបានណែនាំឱ្យពាក់គម្របមុខ ក្នុងខណៈពេលកំពុងស្ថិតនៅក្នុងកន្លែង និងបរិវេណនៃកន្លែង។ នេះត្រូវអនុវត្តចំពោះមនុស្សពេញវ័យ និងកុមារអាយុលើសពី ២ ឆ្នាំ។ មានតែបុគ្គលដែលមានជំងឺផ្លូវដង្ហើមរ៉ាំរ៉ៃ ឬមានលក្ខ័ណ្ឌវេជ្ជសាស្ត្រផ្សេងទៀត ដែលធ្វើឱ្យការប្រើប្រាស់គម្របមុខមានគ្រោះថ្នាក់ ត្រូវបានលើកលែងពីតម្រូវការនេះ។ ប្រសិនបើអាចធ្វើទៅបាន, គម្របមុខត្រូវបានផ្តល់អោយទៅភ្ញៀវទេសចរណ៍ណា ដែលមកដល់ដោយគ្មានគម្របមុខ។
- ☐ ភ្ញៀវទេសចរណ៍ដែលមកដល់កន្លែងជាមួយកុមារ ត្រូវធានាថាកូនៗរបស់ពួកគេនៅក្បែរឪពុកម្តាយ, ជៀសវាងការប៉ះពាល់ជាមួយមនុស្សផ្សេងទៀត ឬរបស់របរដែលមិនមែនជារបស់ពួកគេ, ហើយពាក់គម្របមុខ ប្រសិនបើដល់អាយុត្រូវពាក់។
- ☐ មគ្គុទ្ទេសក៍វិចិត្រសាលដែលអាចប្រើឡើងវិញបាន ត្រូវបានដកចេញហើ យជំនួសដោយផែនទី និងមគ្គុទ្ទេសក៍ប្រើតែម្តងវិញ, សញ្ញា ឬមគ្គុទ្ទេសក៍អូឌីយ៉ូសំឡេង ដែលអាចចូលមើលឬយកបាន តាមរយៈឧបករណ៍អេឡិចត្រូនិកផ្ទាល់ខ្លួន។
- ☐ ចំពោះវិសាលភាពដែលស៊ីសង្វាក់គ្នាទៅនឹងកាតព្វកិច្ចរបស់កន្លែង ចំពោះបុគ្គលដែលមានពិការភាព, ការប្រើប្រាស់កាសអូឌីយ៉ូត្រចៀក និងឧបករណ៍ផ្សេងទៀត ដែលបានអោយទៅកាន់អតិថិជន/ភ្ញៀវទេសចរណ៍ខ្ចី ត្រូវបានបញ្ឈប់ លុះត្រាតែពួកគេ អាចត្រូវបានរំងាប់មេរោគបានត្រឹមត្រូវ បន្ទាប់ពីការប្រើប្រាស់ម្តងៗ។ ពិគ្រោះជាមួយអ្នកផលិតគ្រឿងបរិក្ខារ ដើម្បីកំណត់នូវជំហ៊ាននានា នៃការរំងាប់មេរោគសមស្រប, ជាពិសេសសម្រាប់ផ្ទៃដែលទន់, អាចជ្រាបបាន ដូចជាស្នោពាក់ត្រចៀក កុំអោយត្រជាក់។
- ☐ មានទឹកធ្វើអនាម័យដៃ, ក្រដាស់ស្ពើង និងធុងសំរាម សម្រាប់សាធារណៈជន នៅឬក្បែរច្រកចូលកន្លែង និងនៅជិតតំបន់ដែលអាហារ និងភេសជ្ជៈត្រូវបានផ្តល់អោយ។
- ☐ គ្រឿងបរិក្ខារអនាម័យសម្រាប់និយោជិក និងភ្ញៀវ ត្រូវអោយនៅមានដំណើរការ និងមានស្តុកទុកគ្រប់ពេល ហើយសាប៊ូ, កន្សែងក្រដាស, និងទឹកធ្វើអនាម័យដៃបន្ថែម ត្រូវបានផ្តល់ជូន នៅពេលដែលចាំបាច់។
- ☐ ទីធ្លាសួនកុមារ, រចនាសម្ព័ន្ធដែលឡើងភ្នំទាំងអស់, ផ្ទះដែលរុំព័ទ្ធលោត, ។ល។ ត្រូវបានបិទ ស្របតាមគោលការណ៍ណែនាំរបស់រដ្ឋ ដោយសារតំបន់ទាំងនេះ លើកកម្ពស់ការប្រមូលផ្តុំ និងពិបាកក្នុងការរំងាប់មេរោគ។
- ☐ ការតាំងពិព័រណ៍អន្តរកម្មទាំងអស់, រួមទាំងពិពណ៌ ឬការតាំងសត្វចិញ្ចឹម/ប៉ះ នៅក្នុងអាងចិញ្ចឹមត្រី, អាចនៅតែបើក ប្រសិនបើនិយោជិក ត្រូវបានចាត់ឱ្យអនុវត្តការត្រួតពិនិត្យហ្វូងមនុស្សដែលចាំបាច់ និងធ្វើការរំងាប់មេរោគ រវាងការប្រើប្រាស់នានា។ កន្លែងលាងដៃ និង/ឬទឹកធ្វើអនាម័យដៃ ត្រូវបានបង្កើតឡើងនៅតាមស្ថានីយ៍ទាំងនេះ, ហើយស្នើសុំឱ្យភ្ញៀវទេសចរណ៍ ប្រើ

វាមុននិងក្រោយ ពេលធ្វើអន្តរកម្មជាមួយពិពណ៌សត្វចិញ្ចឹម/ប៉ះ។ ពិចារណាឱ្យបានម៉ត់ចត់ដើម្បីបិទពិពណ៌ទាំងនេះ នៅពេលណាដែលអាចធ្វើទៅបាន, ជាពិសេសនៅពេលកុមារទំនងជាមានអន្តរៈទំនាក់ទំនងជាមួយ ឬចែករំលែកការប្រើប្រាស់វត្ថុតាំង ដោយគ្មានការរំងាប់មេរោគ និងធ្វើអនាម័យដៃ បានត្រឹមត្រូវនោះទេ។

- ❑ ដើម្បីកាត់បន្ថយហានិភ័យនៃជំងឺរលាកសួតធ្ងន់ធ្ងរ (Legionnaires) និងជំងឺនានាផ្សេងទៀត ដែលទាក់ទងទៅនឹងទឹក, ចាត់វិធានការដើម្បីធានាថា ប្រព័ន្ធទឹក និងផ្នែកសំខាន់នានា មានសុវត្ថិភាពក្នុងការប្រើប្រាស់ បន្ទាប់ពីការបិទទីតាំងយូរ។
- ❑ ស្រេចលើចិត្ត - រៀបរាប់ពីវិធានការណ៍ផ្សេងទៀត (ឧទាហរណ៍, ការផ្តល់ជូនតែម៉ោងសំរាប់មនុស្សចាស់ តែប៉ុណ្ណោះ):

_______________________________________________

## D. វិធានការណ៍នានា ដែលទំនាក់ទំនងទៅកាន់សាធារណៈជន

- ❑ ច្បាប់ចតចំលងនៃពិធីការនេះ ត្រូវបានបិទផ្សាយនៅតាមច្រកចូលសាធារណៈ នៅតាមកន្លែងនានា។
- ❑ ស្លាកសញ្ញានៅច្រកចូល ជូនដំណឹងអតិថិជនអំពីដែនកំណត់ ឬកំរឹតនៃការកាន់កាប់។
- ❑ សញ្ញា ត្រូវបានដាក់បង្ហាញនៅតាមច្រកចូលនានា, តំបន់រងចាំ, និងនៅតាមទីធ្លា វិចិត្រសាល និងទីធ្លាសារមន្ទីរ ដើម្បីរំលឹកដល់អ្នកទេសចរណ៍ អំពីច្បាប់ដែលត្រូវធ្វើជាលក្ខខណ្ឌនៃការចូល។ ច្បាប់នេះអាចមានការណែនាំ អំពីការប្រើប្រាស់ទឹកធ្វើអនាម័យដៃ ក៏ដូចជាតម្រូវការពាក់គម្របមុខ ក្នុងកំឡុងពេលទស្សនៈកិច្ច, រក្សាការឃ្លាតឆ្ងាយ រាងកាយពីគ្នា ពីនិយោជិក និងភ្ញៀវ/ក្រុមផ្សេងទៀត, និងជៀសវាងការប៉ះពាល់មិនចាំបាច់លើផ្ទៃ, ។ល។ នៅពេលណាដែលអាចធ្វើទៅបាន, ច្បាប់នេះអាចរកបានតាមបែបឌីជីថល និងរួមបញ្ចូលទាំងការប្រើរូបតំណាង។
- ❑ សញ្ញាសម្គាល់ត្រូវបានបិទផ្សាយដែលណែនាំអ្នកទេសចរណ៍ ថាពួកគេគួរតែស្នាក់នៅផ្ទះ ប្រសិនបើឈឺដោយរោគសញ្ញាផ្លូវដង្ហើមនានា។
- ❑ អនឡាញអៅឡែតនៃទីកន្លែង (គេហទំព័រ, ប្រព័ន្ធផ្សព្វផ្សាយសង្គម ។ល។) ផ្តល់នូវព័ត៌មានច្បាស់លាស់អំពី អំពីម៉ោងពេល ទីកន្លែងឬគ្រឹះស្ថាន, តម្រូវការប្រើប្រាស់គម្របមុខ, ការកាន់កាប់ដែលមានកំណត់/កំរឹត, គោលនយោបាយទាក់ទងនឹងការលក់សំបុត្រ, ការចូល, ការបញ្ជាទិញជាមុន, ការទូទាត់ជាមុន, ការមកទទួល និង/ឬការចែកចាយ/បញ្ជូនអោយ និងបញ្ហាពាក់ព័ន្ធផ្សេងទៀត។
- ❑ ដាក់ឬផ្តល់ស្លាកសញ្ញានៅច្រកចូលសាធារណៈនៃកន្លែងនីមួយៗ ដើម្បីជូនដំណឹងដល់និយោជិក និងអតិថិជនទាំងអស់ថា ពួកគេគួរតែ: (i) ចៀសវាងចូលទៅក្នុងកន្លែង ឬគ្រឹះស្ថាន ប្រសិនបើពួកគេក្អកឬក្តៅខ្លួន; (ii) រក្សាចម្ងាយអប្បបរមាប្រាំមួយហ្វីត ពីម្នាក់ទៅម្នាក់; (iii) កណ្តាស់ និងក្អកដាក់ក្នុងក្រណាត់ ឬក្រដាសស្តើង ឬ, ប្រសិនបើមិនមានទេ, ចូលទៅក្នុងកែងដៃរបស់ខ្លួន; និង (iv) កុំចាប់ដៃ ឬចូលរួមទាក់ទងនឹងរាងកាយនរណាម្នាក់ ដែលមិនចាំបាច់។

**ដើម្បីរាយការណ៍ការបំពាន**
**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**
**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**

## E. វិធានការណ៍នានា ដែលធានានូវការទទួលបានសេវាកម្មចាំបាច់ ប្រកបដោយសមធម៌

- ❑ សេវាកម្មនានាដែលមានសារៈសំខាន់សម្រាប់អតិថិជន/ភ្ញៀវ ត្រូវបានផ្តល់អាទិភាព។
- ❑ នៅកន្លែងដែលអាចធ្វើទៅបាន, កន្លែងស្នាក់នៅ ត្រូវបានបង្កើតឡើងសម្រាប់ប្រជាជនដែលងាយរងគ្រោះ ដើម្បីទទួលបាននូវសេវាកម្មនានា (ឧទាហរណ៍, ការផ្តល់ជូនម៉ោង សំរាប់តែមនុស្សចាស់ប៉ុណ្ណោះ)។
- ❑ ប្រតិបត្តិការ ឬសេវាកម្មដែលអាចត្រូវបានផ្តល់ជូនពីចម្ងាយ ត្រូវបានផ្លាស់ប្តូរនៅលើអ៊ីនធឺណិត។
- ❑ វិធានការណ៍នានា ត្រូវបានបង្កើតឡើង ដើម្បីធានានូដើម្បីធានាបាននូវការទទួលបាននូវទំនិញ និងសេវាកម្ម សម្រាប់អតិថិជនដែលមានកម្រិតនៃការចល័ត និង/ឬមានហានិភ័យខ្ពស់នៅក្នុងទីធ្លាសាធារណៈ។

**វិធានការណ៍បន្ថែមណាមួយ ដែលមិនបានដាក់បញ្ចូលខាងលើ គួរតែត្រូវបានដាក់រាយនៅលើទំព័រដាច់ដោយឡែក, ដែលអាជីវកម្ម គួរតែភ្ជាប់ជាមួយនឹងឯកសារនេះ។**

**អ្នកអាចទាក់ទងមនុស្សខាងក្រោមនេះ បើសិនជាអ្នកមានសំណួរ ឬយោបល់នានា អំពីពិធីការនេះ:**

**ឈ្មោះទំនាក់ទំនងអាជីវកម្ម:** ______________________________

**លេខទូរស័ព្ទ:** ______________________________

**កាលបរិច្ឆេទកែប្រែចុងក្រោយ:** ______________________________

**ដើម្បីរាយការណ៍ការបំពាន**
**សូមទូរស័ព្ទទៅកាន់: (562) 570-2633 ឬ**
**អ៊ីម៉ែល: CETASKFORCE@LONGBEACH.GOV**